# បទបង្ហាញ
# ស្តីពី
# ទស្សនវិស័យនៃការកែទម្រង់រដ្ឋបាលសាធារណៈនិងការផ្សារភ្ជាប់ជាមួយនឹងកំណែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល

ភ្នំពេញថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# មាតិកា

- យុទ្ធសាស្ត្រចក្រកោណដំណាក់កាលទី ៣
- ចក្ខុវិស័យវិស័យនិងវិសាលភាពនៃកំណែទម្រង់រដ្ឋបាលសាធារណៈ
- សូចនាករគោលនៃកំណែទម្រង់រដ្ឋបាលសាធារណៈ
- បទពិសោធន៍នៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- បញ្ហាប្រឈមចំបងៗ
- អ្វីខ្លះគួរអនុវត្តនាពេលខាងមុខ ?




# កែទម្រង់
# គឺរស់
# មិន
# កែទម្រង់
# គឺស្លាប់

# យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣

យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពការងារនៅកម្ពុជា

# យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣

- អភិបាលកិច្ចជាស្នូលនៃការធានាឱ្យមាននូវយុត្តិធម៌សង្គម និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយសមធម៌និងចីរភាព
- កំណែទម្រង់ជាគន្លឹះរួមមាន៖ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការកែទម្រង់ដីធ្លី ព្រៃឈើ និងជលផល។

# ចក្ខុវិស័យនិងវិសាលភាពនៃកំណែទម្រង់រដ្ឋបាលសាធារណៈ

“ប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ដែលអាចជឿទុកចិត្តបានសំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង”

# វិសាលភាពនៃកំណែទម្រង់រដ្ឋបាលសាធារណៈ

**យុទ្ធសាស្រ្តចតុកោណ**
**ដំណាក់កាលទី៣**

- ការកែលម្អសេវាសាធារណៈ
- ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស
- ការកែទម្រង់ប្រព័ន្ធបៀវត្ស



# សេវាសាធារណៈ

សេវាសាធារណៈប្រកបដោយ៖

- គុណភាព
- មានភាពសាមញ្ញ
- ប្រសិទ្ធភាព
- ភាពអាចជឿទុកចិត្តបាន
- ឆាប់រហ័សឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការ
- មានភាពងាយស្រួល និង
- មានការចូលរួមពីអ្នកប្រើប្រាស់សេវា

# ការគ្រប់គ្រងនិងអភិវឌ្ឍមន្ត្រីរាជការស៊ីវិល

ការគ្រប់គ្រងនិងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមាន៖

- សមត្ថភាព
- ភាពស្វាហាប់
- ប្រសិទ្ធភាព
- ភាពជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ
- ប្រកាន់ភ្ជាប់នូវវប្បធម៌សេវាសាធារណៈ
- ឆន្ទៈម្ចាស់ការ
- ភក្តីភាព និង
- មនសិការវិជ្ជាជីវៈ

# ប្រព័ន្ធបៀវត្ស

ប្រព័ន្ធបៀវត្សដែលធានាបាននូវ៖
- សមធម៌
- បង្កើនផលិតភាព
- ប្រសិទ្ធភាពការងារ និង
- សង្គតិភាពរវាងក្រុមខណ្ឌមន្ត្រីរាជការស៊ីវិលនិងក្រុមខណ្ឌកងកម្លាំងប្រដាប់អាវុធ



# ការកែទម្រង់ ប្រៀបបានការធ្វើ ដំណើរឆ្លងកាត់ ទន្លេ ដែលត្រូវ បោះជំហានដោយ ស្ទាបថ្មក្រោមទឹក

# សូចនាករគោលនៃកំណែទម្រង់រដ្ឋបាល

១.	មុខងារសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំជាអង្គវិជ្ជាជីវៈ និងមានការកំណត់មុខតំណែងនិងការពិពណ៌នាមុខតំណែងច្បាស់លាស់

២.	ការកសាងសមត្ថភាពមន្ត្រីរាជការមានប្រសិទ្ធភាពនិងមានប្រព័ន្ធវាយតម្លៃច្បាស់លាស់

៣.	ប្រព័ន្ធបៀវត្សមន្ត្រីរាជការមានសង្គតិភាពសមធម៌ និងគាំទ្រផលិតភាព

# សូចនាករគោលនៃកំណែទម្រង់រដ្ឋបាល

១. មុខងារសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំជាអង្គវិជ្ជាជីវៈ និងមានការកំណត់មុខតំណែងនិងការពិពណ៌នាមុខតំណែងច្បាស់លាស់

២. ការកសាងសមត្ថភាពមន្ត្រីរាជការមានប្រសិទ្ធភាពនិងមានប្រព័ន្ធវាយតម្លៃច្បាស់លាស់

៣. ប្រព័ន្ធបៀវត្សមន្ត្រីរាជការមានសង្គតិភាពសមធម៌ និងគាំទ្រផលិតភាព

# សូចនាករគោលនៃកំណែទម្រង់រដ្ឋបាល

៤.ការវិភាគមុខងារ និងការត្រួតពិនិត្យប្រតិបត្តិការឡើងវិញរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត និងធ្វើវិចារណកម្ម

៥.ប្រព័ន្ធគ្រប់គ្រងគុណផលការងារ និងប្រព័ន្ធលើកទឹកចិត្ត ត្រូវបានដាក់ឱ្យដំណើរការ

៦.ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត

# សូចនាករគោលនៃកំណែទម្រង់រដ្ឋបាល

៧. ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានដាក់អនុវត្តគ្រប់ក្រសួងស្ថាប័ន

៨. ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានពង្រីកជាលំដាប់

៩. ការកើនឡើងនៃមន្ត្រីរាជការជាស្ត្រីក្នុងមុខងារសាធារណៈ និងក្នុងកម្រិតគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## សូចនាករ ១៖ មុខងារសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំជាអង្គវិជ្ជាជីវៈ និងមានការកំណត់មុខតំណែងនិងការពិពណ៌នាមុខតំណែងច្បាស់លាស់

- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអង្គរដ្ឋបាលស្ថិតក្នុងការពិភាក្សាផ្ទៃក្នុងក្រសួង
- មុខតំណែងនិងការពិពណ៌នាមុខតំណែងមិនទាន់អនុវត្តបានពេញលេញ
- ការរៀបចំផែនការធនធានមនុស្សប្រចាំឆ្នាំត្រូវបានកែលម្អជាប្រចាំ

# សូចនាករ២.   ការកសាងសមត្ថភាពមន្ត្រីរាជការមានប្រសិទ្ធភាពនិងមានប្រព័ន្ធវាយតម្លៃច្បាស់លាស់

- បានអនុវត្តការវាយតម្លៃអំពីសេចក្តីត្រូវការនៃការបណ្តុះបណ្តាល
- ការបណ្តុះបណ្តាលត្រូវបានអនុវត្តនិងបន្តអនុវត្ត
- ការកសាងសមត្ថភាពមិនទាន់ត្រូវបានគិតគូរនិងរៀបចំជាលក្ខណៈប្រព័ន្ធនិងមានការវាយតម្លៃច្បាស់លាស់

# សូចនាករ៣.   ប្រព័ន្ធបៀវត្សមន្ត្រីរាជការមាន សង្គតិភាព សមធម៌ និងគាំទ្រផលិតភាព

- បៀវត្សត្រូវបានធ្វើឱ្យមានសង្គតិភាព ធានានូវ សមធម៌ និងដំឡើងតាមផែនការ
- បន្ទុកបៀវត្សមានការកើនឡើង ទន្ទឹមនឹងការផ្តល់ សេវាសាធារណៈ មិនទាន់ត្រូវបានលើកកម្ពស់ឱ្យ បានសមស្រប
- ការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីមិនទាន់អស់ សក្តានុពល និងមិនមានប្រសិទ្ធភាព នាំឱ្យ មានផលប៉ះពាល់ខ្លាំងដល់គោលនយោបាយ ដំឡើងបៀវត្ស

# សូចនាករ៤.   ការវិភាគមុខងារ និងការត្រួតពិនិត្យប្រតិបត្តិការឡើងវិញរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត និងធ្វើវិចារណកម្ម

- ការវិភាគមុខងារ ការត្រួតពិនិត្យរំហូរការងារនិងប្រតិបត្តិការ អនុវត្តបានកម្រិតសូចស្តើង
- ការបង្កើត និងការពង្រីកអង្គភាព ស្ថាប័ន មាននិន្នាការកើនឡើង
- ការធ្វើវិចារណកម្មមុខងារនិងប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន និងអង្គភាព មិនទាន់ត្រូវបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់

# សូចនាករ៩. ប្រព័ន្ធគ្រប់គ្រងគុណផលការងារ និងប្រព័ន្ធលើកទឹកចិត្ត ត្រូវបានដាក់ឱ្យដំណើរការ

- ការគ្រប់គ្រងគុណផលការងាររបស់មន្ត្រី និងស្ថាប័ន នៅមិនទាន់អនុវត្តឱ្យបានទូលំទូលាយ និងជាក់ស្តែង
- ការលើកទឹកចិត្តក្នុងរដ្ឋបាលសាធារណៈ មិនទាន់អនុវត្តបានប្រសើរ

# សូចនាករ៦.    ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត

- ព័ត៌មានសអំពីសេវាសាធារណៈត្រូវបានប្រមូលចងក្រងនិងផ្សព្វផ្សាយ
- ការត្រួតពិនិត្យនិងវាយតម្លៃគុណភាពនៃការផ្តល់សេវាសាធារណៈ នៅមានកម្រិតទាប
- ស្ថាប័នទទួលអាណត្តិក្នុងការត្រួតពិនិត្យនិងវាយតម្លៃអំពីការផ្តល់សេវាមិនទាន់ត្រូវបានកំណត់ច្បាស់លាស់

## សូចនាករ៧. ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានដាក់អនុវត្តគ្រប់ក្រសួង ស្ថាប័ន

- ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការត្រូវបានធ្វើបច្ចុប្បន្នភាពជាបណ្តើរៗ
- ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាត្រូវបានដាក់ឱ្យអនុវត្ត
- ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការបង្រៀនម៉ោងបន្ថែមត្រូវបានរៀបចំជាបណ្តើរៗ

# ស្នូចនាករ៨. ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានពង្រីកជាលំដាប់

- ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានអនុវត្តជាបណ្តើរៗ និងមាននិន្នាការកើនឡើងជាលំដាប់
- ការផ្តល់ព័ត៌មានតាមប្រព័ន្ធទំនាក់ទំនងសង្គម មានកំណើនល្អ
- ការកសាងសមត្ថភាពមន្ត្រីអំពីការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានអនុវត្តជាបន្តបន្ទាប់

# សូចនាករ៩. ការកើនឡើងនៃមន្ត្រីរាជការជាស្ត្រីក្នុងមុខងារសាធារណៈ និងក្នុងកម្រិតគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- ចំនួនស្ត្រីមានការកើនឡើងក្នុងរដ្ឋបាលសាធារណៈ
- ការកសាងសមត្ថភាពស្ត្រីត្រូវបានផ្តល់ការយកចិត្តទុកដាក់កាន់តែប្រសើរ

# បទពិសោធន៍នៃការអនុវត្តកំណែទម្រង់

- ការកំណត់យុទ្ធសាស្ត្រកែទម្រង់ត្រឹមត្រូវនិងច្បាស់លាស់ពីដំបូង និងផ្តើកលើចក្ខុវិស័យវែងឆ្ងាយ
- ភាពជាអ្នកដឹកនាំនិងការគាំទ្ររបស់ប្រធានស្ថាប័នចំពោះការអនុវត្តសកម្មភាពកែទម្រង់
- សមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ឫរេសកម្ម និងភាពសកម្មរបស់មន្ត្រីជំនាញចំពោះការងារកែទម្រង់ និងស្មារតីការងារជាក្រុម
- សមត្ថភាពនៃការសម្របសម្រួលផ្ទៃក្នុង អន្តរវិស័យ និងជាមួយដៃគូអភិវឌ្ឍន៍របស់ក្រុមការងារបច្ចេកទេស

# បទពិសោធន៍នៃការអនុវត្តកំណែទម្រង់

- ការសម្របសម្រួលនិងការគាំទ្រគ្នាទៅវិញទៅមកនៃកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃការងារកែទម្រង់ជាប្រចាំ។


HOW TO BE
A
SUCCESS
HARD WORK

# បញ្ហាប្រឈមចំបងៗ

- មុខងារ រចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងអង្គភាពនីងរបៀបការងារក្នុងរដ្ឋបាល មិនទាន់ត្រូវបានធ្វើការត្រួតពិនិត្យនិងកែលម្អឡើងវិញឱ្យបានច្បាស់លាស់និងស៊ីជម្រៅ
- ធនធានមនុស្សប្រកបដោយគុណភាពនិងគុណធម៌ដើម្បីបំពេញការងារក្នុងរដ្ឋបាលសាធារណៈនៅតែជាបញ្ហាប្រឈម
- ភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ នៅមានកម្រិត មិនអាចឆ្លើយតបពេញលេញនឹងការវិវត្តរបស់សង្គម


MCKENNA

# អ្វីខ្លះគួរអនុវត្តនាពេលខាងមុខ?

- ពង្រឹងការផ្សារភ្ជាប់ឱ្យកាន់តែជិតស្និទ្ធនិងរឹងមាំរវាងការដឹកនាំនិងតម្រង់ទិសកម្រិតនយោបាយនិងការដឹកនាំនិងប្រតិបត្តិកម្រិតបច្ចេកទេស
- ការត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ ព្រមទាំងលិខិតបទដ្ឋាននិងវិធានការក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ ត្រូវអនុវត្តឱ្យបានជាទៀងទាត់
- ត្រូវពិនិត្យនិងកំណត់សកម្មភាពការងារជាជំហានៗឱ្យបានច្បាស់លាស់ ប្រាកដនិយម លទ្ធផលវាស់វែងបាន ព្រមទាំងនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានឆាប់រហ័សចំពោះប្រព័ន្ធ

# អ្វីខ្លះគួរអនុវត្តនាពេលខាងមុខ?

- ពង្រឹងយន្តការសម្របសម្រួលផ្នែកបច្ចេកទេសរវាងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលដើម្បីកំណត់សកម្មភាពការងាររួម ឬ សកម្មភាពដែលមានភាពប្រទាក់ក្រឡាគ្នា ឬគាំទ្រគ្នាទៅវិញទៅមក៖
  - អង្គភាពថវិកា ថវិកាកម្មវិធី
  - ការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល
  - ការកសាងសមត្ថភាពមន្ត្រី
  - ការវិភាគមុខងារ ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
  - ការកំណត់របបលើកទឹកចិត្តក្នុងរដ្ឋបាល
  - របៀបការងារក្នុងការផ្តល់សេវាសាធារណៈ…

# អ្វីខ្លះគួរអនុវត្តនាពេលខាងមុខ?

- រៀបចំឱ្យមានយន្តការត្រួតពិនិត្យនិងវាយតម្លៃជាទៀងទាត់លើលទ្ធផលនិងផលប៉ះពាល់នៃការអនុវត្តកម្មវិធីកែទម្រង់ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា
- ពង្រឹងភាពជាអ្នកដឹកនាំដល់មន្ត្រីគ្រប់គ្រងនៅគ្រប់កម្រិតទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈការតែងតាំង ការកសាងសមត្ថភាព និងការគាំទ្រផ្សេងៗ។




# មិនមានអ្វី
# ដែលថា
# មិនអាចធ្វើ
# បាននោះទេ

# សូមអរគុណ